សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ

# មុខវិជ្ជា៖
# ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ

**កញ្ចប់សមត្ថភាពទី២**

**ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន**







# មុខវិជ្ជា៖
# ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ

កញ្ចប់សមត្ថភាពទី ២

ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន

## ការពណ៌នាអំពីមុខវិជ្ជា

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖
លទ្ធផលសិក្សារំពឹងទុកទី ២៖
លទ្ធផលសិក្សារំពឹងទុកទី ៣៖
លទ្ធផលសិក្សារំពឹងទុកទី ៤៖
លទ្ធផលសិក្សារំពឹងទុកទី ៥៖

**វាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%
២. ការចូលរួមសកម្មភាពសិក្សា ២០%
៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%
៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖

កិច្ចការទី ២៖

កិច្ចការទី ៣៖

កិច្ចការទី ៤៖

កិច្ចការទី ៥៖

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ កក្កដា ឆ្នាំ២០២២
**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេស កម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃរង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញត្តិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រេឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និងដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

## គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

# "ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ"

ក្រសួងអប់រំ យុវជន និងកីឡា

គម្រោងកែលម្អការអប់រំចំណេះទូទៅ (General Education Improvement Project- GEIP)

## វត្ថុបំណង

- សិក្ខាកាមមានសមត្ថភាពលើការសិក្សារៀនសូត្រ PL (Professional Learning) ក្នុងការៈ
  - ✓ កត់ត្រា
  - ✓ ចងក្រង និង
  - ✓ វិភាគទិន្នន័យសុចរិតភាពគាំទ្រដល់ការបង្រៀននិងរៀន និង
  - ✓ កែលម្អការគ្រប់គ្រងរដ្ឋបាលសាលារៀន







1. ***ទទួលការយល់ដឹងថ្មីពីកិច្ចការថ្មីមួយ៖***
   - *បង្កើតការយល់ឃើញថាមានបញ្ហាប្រឈម (គោលនយោបាយ៖ (ក្របខណ្ឌគោលនយោបាយសង្គមសេដ្ឋកិច្ចឌីជីថល, គោលនយោបាយរដ្ឋាភិបាលឌីជីថល, យុទ្ធសាស្ត្រសុខដុមនីយកម្មពាបូក ១)*
   - *បង្កើតសម្ព័ន្ធភាពនាំមុខ (ពិភាក្សាជាមួយ PL និងសាលារៀនពាក់ព័ន្ធដើម្បីត្រៀមរៀបចំធ្វើបច្ចុប្បន្នកម្មទិន្នន័យ ស្មោះត្រង់នឹងខ្លួនឯង និងប្រព័ន្ធទាំងមូល)*
2. ***ទទួលបាននូវការកែប្រែអត្តចរិតនិងចរិយាថ្មីពីកិច្ចការថ្មីមួយ៖***
   - *រៀបចំឱ្យមានចក្ខុវិស័យច្បាស់លាស់៖ ពិភាក្សាលើកិច្ចការត្រូវធ្វើសម្រាប់ PL និងសាលារៀនពាក់ព័ន្ធ (បេសកកម្ម និង គោលបំណង) ជាមួយនឹងរបៀបអនុវត្តពីសាលារៀនមួយទៅសាលារៀនមួយទៀត*
   - *ចែករំលែកចក្ខុវិស័យដល់មនុស្សទាំងអស់៖ ប្រជុំជាមួយ PL និងសាលារៀនពាក់ព័ន្ធ ពីចក្ខុវិស័យ បន្ថែមនូវការប្តេជ្ញាចិត្តនិងកំណត់កិច្ចការត្រូវធ្វើដោយបុគ្គលម្នាក់ៗ និងយុទ្ធសាស្ត្រសហគមន៍សាលារៀន*

## លទ្ធផលរំពឹងទុក...

3. *កសាងបាននូវពិសោធន៍ និងចំណេះដឹងថ្មីកិច្ចការថ្មីមួយៈ*
   - *កសាងការទុកចិត្តនិងផ្តល់អំណាចជំនះឧបសគ្គ៖ កិច្ចការ និងអំណាចសម្រេចចិត្ត បង្រៀន និងបង្ហិកដើម្បីអាចកត់ត្រា ចងក្រង វិភាគ សរសេររបាយការការណ៍លទ្ធផលឬសមិទ្ធកម្ម និងប្រើប្រាស់សុចរិតភាពទិន្នន័យ*
   - *ជានាផលិតភាពជោគជ័យក្នុងរយៈពេលខ្លី ៖ បរិបទនៃភាពជោគជ័យ ខ្លឹមសារត្រូវបានចងក្រងជាទិន្នន័យព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តគោលនយោបាយ*
4. *ទទួលបាននូវការកែប្រែអត្តចរិតនិងចរិយាថ្មីពីកិច្ចការថ្មីមួយៈ*
   - *សរុបភាពជោគជ័យ និងរក្សាអនុវត្តបន្ត៖ ចែករំលែកភាពជោគជ័យក្នុងសហគមន៍សាលារៀនដែលខ្លួនទទួលខុសត្រូវ និងបន្តជួយដល់សាលារៀនផ្សេងទៀតនៅក្នុងសហគមន៍ និងឈានទៅស្រុកសាលារៀន*
   - *បណ្តុះការផ្លាស់ប្តូរឱ្យរឹងមាំ៖ សរុបឡើងវិញនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីកសាងផែនការពង្រីកវិសាលភាពប្រែក្លាយសហគមន៍សាលារៀនទៅជាស្រុកសាលារៀន*

## ផលសម្រេច

**1**

កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅគ្រប់កម្រិតអប់រំចំណេះទូទៅ នៅកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការស្តង់ដាអប់រំនៅក្នុងស្រុក និងតំបន់ ដើម្បីគាំទ្រដល់ភស្តុតាង និងសក្ខីកម្មដល់អ្នកធ្វើការសម្រេចចិត្ត ក្នុងការរៀបចំគោលនយោបាយអប់រំប្រកបដោយប្រសិទ្ធភាព

**2**

បង្កើតក្រុមបណ្តាញក្នុងប្រទេសដើម្បីចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តនៃការការគ្រប់គ្រងទិន្នន័យការអប់រំចំណេះទូទៅ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការសម្រេចចិត្តនៅក្នុងវិស័យអប់រំ។

# ការគ្រប់គ្រងទិន្នន័យ

*យើងធ្វើការឆ្លុះបញ្ចាំងជារួមមើលថាតើ មានអ្វីចាំបាច់ដែលយើងត្រូវសិក្សាពីទិន្នន័យ?*



# អំពីប្រវត្តិសាស្ត្រ

- *តើយើងដឹងទេថាតើអង្គរវត្តសាងសង់យ៉ាងដូចម្ដេច ?*
- *តើប្រវត្តិសាស្ត្របានប្រាប់យើងពីអ្វី ?*
- *តើយើងកំពុងដើរតាមគន្លងប្រវត្តិសាស្ត្រឬទេ ?*
- *ហើយវាជាអ្វីដែលយើងដឹងប្រាកដថាវាត្រូវ ?*







## ប្រព័ន្ធអប់រំវិញ

- ដោយឡែកសម្រាប់ប្រព័ន្ធអប់រំវិញ តើយើងដឹងថាវាមានដំណើរការយ៉ាងណាតាំងពី៖
  - ១,២០០ឆ្នាំមុន ? ៥០០ឆ្នាំមុន ? ២០០ឆ្នាំមុន ?
  - ៤០ ឬ៣០ឆ្នាំមុន ? ឬក៏៥ ឆ្នាំមុន ? ឬ១ឆ្នាំមុន ?

# ស្ថានភាពទូទៅ នៃគ្រឹះស្ថានសិក្សាសាធារណៈ

**តើលោក លោកស្រី ដែលជាសិក្ខាកាមទាំងអស់ បានដឹងអ្វីខ្លះពីគ្រឹះស្ថានសិក្សាសាធារណៈ ?**

## ប្រព័ន្ធអប់រំកម្ពុជា (២០២៣-២០២៤)៖ ប្រព័ន្ធ និងទិន្នន័យ







- ប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលើការអប់រំ ដោយឈរលើគោលការណ៍ «ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»។ *«ធានាថាប្រជាជនកម្ពុជាទាំងអស់ទទួលបានការអប់រំប្រកបដោយ បរិយាបន្ននិងសមធម៌ ជាមួយនឹងចំណេះដឹង ជំនាញ និងគុណតម្លៃដែលនាំទៅរកសុខភាពល្អ កាយ សម្បទា និងការសិក្សាពេញមួយជីវិត»។*
- ពង្រឹងសមត្ថភាពស្ថាប័ន ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានា ភាពស័ក្តិសិទ្ធិនៃការដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ *(កម្មវិធីទី ៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ-កិច្ចការត្រូវធ្វើ, ធ្វើត្រូវ, អភិវឌ្ឍ)*

# អត្រារួមនៃការសិក្សាកុមារអាយុ ៣-៥ ឆ្នាំ (២០១៣-២០១៤ ដល់ ២០២២-២៣)




13

# អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ ឆ្នាំសិក្សា២០១៣-២០១៤ រហូតដល់២០២២-២០២៣




14

# អត្រាពិតនៃការសិក្សានៅបឋមសិក្សា




15

# អត្រារួមនៃការសិក្សានៅបឋមសិក្សា ឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២០២២-២០២៣




16

## អត្រាបញ្ចប់ការសិក្សា ឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២០២២-២០២៣






## អត្រាគង់វង្សក្នុងការអប់រំបឋមសិក្សាឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ២០២២-២០២៣



## អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣




19

## អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣




20

## អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២២-២០២៣




21

## អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣




22

## ចំនួនសិស្សមធ្យមសិក្សា ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣

### អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ |
|---|---|---|---|---|---|---|---|---|---|---|
| សរុប | ២២.៧៤ | ២០.០០ | ១៩.៤០ | ២១.៤៤ | ២៣.៦០ | ២៣.៦០ | ២៥.៩០ | ២៧.២០ | ៣៥.៦០ | ៤១.៣០ |
| ស្រី | ២២.១០ | ២០.១០ | ១៩.៩៦ | ២២.៦១ | ២៥.៣៩ | ២៦.០០ | ២៩.១០ | ៣០.៨០ | ៣៩.៨០ | ៤៥.៥០ |
| ប្រុស | ២៣.៣៤ | ២០.០០ | ១៨.៨៨ | ២០.៣៦ | ២១.៩៥ | ២១.៣៩ | ២២.៩០ | ២៣.៧០ | ៣១.៧០ | ៣៧.២០ |

23

### អត្រារួមនៃការសិក្សាអាយុ ១៨-២២ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣




24

## ២. លទ្ធផលនៃការលើកកម្ពស់លទ្ធផលនៃការសិក្សារបស់សិស្ស
Enrolment: Students Flow from K-12, AY 2022-2023




25

## និទ្ទេសសិស្សទទួលបានពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរយៈពេល ១០ឆ្នាំកន្លងមក
Grade/ Level of Performance: National G12 Examination (2013-2023)




| | 2013-2014 | 2014-2015 | 2015-2016 | 2016-2017 | 2017-2018 | 2018-2019 | 2020-2021 | 2021-2022 | 2022-2023 |
|---|---|---|---|---|---|---|---|---|---|
| Passing Rate of Grade 12 % | 37.81% | 55.88% | 62.18% | 63.84% | 67.07% | 68.62% | 65.65% | 72.33% | 72.89% |
| Grade A: Total % | 0.03% | 0.23% | 0.73% | 0.67% | 0.54% | 0.56% | 2.43% | 1.15% | 1.70% |
| Grade B % | 0.64% | 2.33% | 5.02% | 3.87% | 2.92% | 3.07% | 7.24% | 7.95% | 7.07% |
| Grade C % | 2.67% | 7.07% | 10.04% | 7.85% | 7.95% | 7.40% | 16.15% | 20.95% | 18.59% |
| Grade D % | 5.55% | 13.09% | 15.85% | 14.33% | 19.96% | 17.84% | 32.63% | 34.27% | 34.78% |
| Grade E % | 91.10% | 77.28% | 68.37% | 73.28% | 68.63% | 71.13% | 41.54% | 35.68% | 37.85% |

Passing Rate of Grade 12 % Grade A: Total % Grade B % Grade C % Grade D % Grade E %

26


ក្រសួង
គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
មន្ទីរអប់រំ
ការិយាល័យអប់រំ
សាលារៀន
គ្រឹះស្ថានឧត្តមសិក្សា
សាលាមធ្យមសិក្សា
សាលាបឋមសិក្សា
សាលាមត្តេយ្យសិក្សារដ្ឋនិងសហគមន៍
ទីផ្សារ
ការងារ
27


កំណែទម្រង់វិស័យអប់រំ-ការកសាងប្រព័ន្ធភាពធន់
(បរិបទការគ្រប់គ្រងសាលារៀនចំពោះឈានទៅឧត្តមសិក្សា)
ភាពធន់ ( ប្រព័ន្ធ )
ការងារ និងកំណើន
៦អា ( 6As )
ការវាយតម្លៃ
Assessment
គណនេយ្យភាព
Accountability
ស្វ័យភាព
Autonomy
យកចិត្តទុកដាក់លើនាយក/គ្រូ
យកចិត្តទុកដាក់លើការអប់រំកុមារតូច/បឋម
យកចិត្តទុកដាក់លើវប្បធម៌/គុណតម្លៃសាលា
ការរៀន ( លទ្ធផល )
ការបង្រៀន ( លទ្ធផល )
ប្រសិទ្ធភាព
ស័ក្តិសិទ្ធភាព
អប់រំកុមារតូច
បឋមសិក្សា
មធ្យមសិក្សា
ឧត្តមសិក្សា
28


ធាតុចូលមានគុណភាព
នាយកសាលារៀន
គ្រូបង្រៀន
មូលនិធិ
គោលនយោបាយ
ប្រើធាតុចូលបានត្រឹមត្រូវ
សិស្សរៀនចេះ
ប្រព័ន្ធដំណើរការប្រទាក់គ្នា
បានទទួលការគាំទ្រពី
រាជរដ្ឋាភិបាល
មាតាបិតា
សហគមន៍
ដៃគូអភិវឌ្ឍ
ទីផ្សារ




ប្រើបច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន និងការគ្រប់គ្រងរដ្ឋបាល
ចំណាយ៣ទៅ៦ខែបង្វិក សិស្សឱ្យរៀនអានពេញល្បឿន ប្រើសន្លឹកកិច្ចការ ជួយសិស្សគេចផុតពីនិទ្ទេស E និងF
ឆ្នាំ២០២៣ បង្រៀនសិស្សបន្តប្រើសន្លឹកកិច្ចការ និងជាគម្រោងសិក្សារៀនស្ទូត្របំណិនកសិកម្ម ជួយសិស្សរៀនបាននិទ្ទេស C និងD
ឆ្នាំ២០២៤ បង្រៀនសិស្សជាគម្រោងវិនិយោគពីបំណិនកម្មន្តសាលកម្ម ជួយសិស្សរៀនបាននិទ្ទេស A និងB
ឆ្នាំ២០២៤និង២០២៥ បន្តរៀនជាគម្រោងវិនិយោគជួយសិស្សកសាងបំណិនសតវត្សទី២១ មានពេញលេញសមត្ថភាពកម្រិតបួម
លុបបំបាត់ឱ្យអស់ចរិយាហិង្សានៅក្នុងថ្នាក់រៀន សាលារៀន និងនៅតាមគ្រួសារ

# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

## កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព

ផ្តោតលើក្រទាំង៣

## ក្ររៀនសូត្រ ក្រចិត្ត ក្រលុយ



## យុទ្ធសាស្ត្រការគ្រប់គ្រងសាលារៀន



## ការវិវត្តន៍ និងការព្យាករណ៍ចំនួនប្រជាជនក្នុងវ័យសិក្សា ឆ្នាំ២០០៨-២០៣០

| គិតជាពាន់ | ២០០៨ | | ២០១៩ | | ២០២៥ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ការបែងចែក | សរុប | ការបែងចែក | សរុប | ការបែងចែក | សរុប | ការបែងចែក |
| ០-២ | ៨០៦ | ៦,០% | ៨០៨ | ៥,២% | ៩២៦ | ៥,៣% | ៨៦២ | ៤,៦% |
| ៣-៥ (មត្តេយ្យសិក្សា) | ៨៦០ | ៦,៤% | ៩៤៧ | ៦,១% | ៩៥៤ | ៥,៤% | ៩២៥ | ៤,៩% |
| ៦-១១ (បឋមសិក្សា) | ១ ៧៨៦ | ១៣,៣% | ១ ៨២៩ | ១១,៨% | ១ ៨៤៣ | ១០,៥% | ១ ៨៨៤ | ១០,១% |
| ១២-១៤ (មធ្យមសិក្សាបឋមភូមិ) | ១ ០៦៤ | ៧,៩% | ៩៨៨ | ៦,៤% | ៩១៩ | ៥,២% | ៩២៧ | ៤,៩% |
| ១៥-១៧ (មធ្យមសិក្សាទុតិយភូមិ) | ៩៧៤ | ៧,៣% | ៨៤០ | ៥,៤% | ១ ០១២ | ៥,៨% | ៨៩៥ | ៤,៨% |
| ១៨-២៣ (ឧត្តមសិក្សា) | ២ ០១៦ | ១៥,១% | ១ ៨២៥ | ១១,៧% | ២ ១៧៨ | ១២,៤% | ២ ៣០១ | ១២,៣% |
| ២៥-៦៤ (ការរៀនពេញមួយជីវិត) | ៥ ៣២៥ | ៣៩,៨% | ៧ ៤០៤ | ៤៧,៦% | ៨ ៤៩៧ | ៤៨,៣% | ៩ ២៩០ | ៤៩,៦% |
| ៦៥+ | ៥៦៥ | ៤,២% | ៩១២ | ៥,៩% | ១ ២៥០ | ៧,១% | ១ ៦៥២ | ៨,៨% |
| ចំនួនប្រជាជនសរុប | ១៣ ៣៩៦ | ១០០% | ១៥ ៥៥២ | ១០០% | ១៧ ៥៧៨ | ១០០% | ១៨ ៧៣៦ | ១០០% |

# "ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ"

ក្រសួងអប់រំ យុវជន និងកីឡា

*គម្រោងកែលម្អការអប់រំចំណេះទូទៅ* (General Education Improvement Project- GEIP)

## តើលោក លោកស្រី ជាគណៈគ្រប់គ្រង ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យ មានទិន្នន័យអ្វីខ្លះ?

- ចំនួន/បញ្ជីឈ្មោះសាលារៀនតាមភូមិសិក្សា
- ចំនួន/បញ្ជីឈ្មោះគណៈគ្រប់គ្រងសាលារៀន
- ចំនួន/បញ្ជីឈ្មោះគ្រូបង្រៀន
- ចំនួន/បញ្ជីឈ្មោះសិស្ស
  - *ពិន្ទុសិស្ស ABCDEF (តេស្តស្តង់ដា)*
  - *សិស្សរៀនយឺត (DEF)*
  - *សិស្សខ្សោយគំហើញ/ស្តាប់/ពិការភាព/ហិង្សា/ក្រីក្រ/គ្រឿងញៀន...*
  - *យន្តការជួយសិស្សរៀនយឺត/លឿន (ការប្រើសន្លឹកកិច្ចការ/បច្ចេកវិទ្យា/*
- បញ្ជីសារពើព័ន្ធ (ទ្រព្យសម្បត្តិរដ្ឋ)
- ចំណូល-ចំណាយ (ហិរញ្ញវត្ថុ/លទ្ធកម្ម)
- ឯកសារចេញ ចូល (រដ្ឋបាល/
  - *ច្បាប់ស្តីពីអប់រំ, យុទ្ធសាស្ត្រនានា, ឯកសារគតិយុត្តនានាគាំទ្រដល់ការអប់រំ*
  - *សេចក្តីប្រកាស សេចក្តីណែនាំ*
  - *បទបញ្ជាផ្ទៃក្នុង*
- **ទិន្នន័យពិនិត្យតាមដាន**
  - សាលាជាប់ស្តង់ដាសាលារៀនគំរូ
  - ការចូលរួមគាំទ្រដោយសហគមន៍
  - ផលជះ

## ចំណោទទិន្នន័យសាលារៀន-តើត្រូវធ្វើដូចម្តេចបើ...

១. លទ្ធផលសិក្សា មិនប្រាកដថាសិស្សម្នាក់ៗមានសមត្ថភាពពិតប្រាកដ មិនអាចទទួលយកបានទាំងអស់គ្នា ដោយសារគ្រូបង្រៀនរៀបចំសំណួរនិងធ្វើតេស្តដោយខ្លួនឯង?

២. សិស្សពុំមានសមត្ថភាពតាមថ្នាក់ដែលកំពុងរៀន និងមិនត្រូវបានទទួលការជួយទាន់ពេល ដោយសារសមត្ថភាពពិតរបស់ខ្លួនមិនត្រូវបានដឹង?

៣. សិស្សពុំមានទឹកចិត្តរៀនសូត្រ ដោយសារមិនយល់ខ្លឹមសារមេរៀននៃថ្នាក់កំពុងរៀន នាំឱ្យសិស្សត្រួតថ្នាក់ និងងាយបោះបង់ការសិក្សា?

៤. សិស្សមិនអាចយល់មេរៀន ពិសេសសាលារៀននៅជនបទនិងតំបន់ដាច់ស្រយាល ដោយសារគ្រូបង្រៀនបង្រៀនខុសមុខវិជ្ជា ព្រោះដោយសារខ្វះគ្រូបង្រៀន?

## ចំណោទទិន្នន័យសាលារៀន-តើត្រូវធ្វើដូចម្តេចបើ...

៥. សិស្សរៀនមិនមានសមត្ថភាពដោះស្រាយបញ្ហាសេដ្ឋកិច្ចនិងសង្គមក្នុងជីវិត ដូចនេះនាំឱ្យការចូលរៀន ពិសេសនៅមធ្យមសិក្សាទាប ហើយការចងចាំតែទ្រឹស្តីនាំសិស្សខ្ជិលរៀន?

៦. សាលារៀននៅទីប្រជុំជននិងទីក្រុងមានបញ្ហាលើសគ្រូ ដោយសារការបន្ថែមគ្រូជារៀងរាល់ឆ្នាំ ដែលនាំឱ្យការប្រើប្រាស់ម៉ោងរជ្ជរបស់គ្រូបង្រៀនមិនបានពេញលេញ (សល់ម៉ោង) នាំជះឥទ្ធិពលឱ្យគ្រូបង្រៀននៅសាលាឯកជន?

៧. ការបែងចែកធនធាន ឱ្យមានសមធម៌នៅខ្សោយ ដោយសារនិយាមសិស្សនិងគ្រូបង្រៀន ខ្ពស់នៅសាលាជនបទ និងទាបនៅទីក្រុងនិងប្រជុំជន?

## ចំណោទនិន្នន័យសាលារៀន-តើត្រូវធ្វើដូចម្ដេចបើ...

៨. **និយាមសិស្សនិងថ្នាក់រៀន** សិស្សច្រើនហួសហេតុនៅទីក្រុងនិងប្រជុំជន និងខ្វះបន្ទប់រៀនតែម្ដងនៅជនបទនិងតំបន់ដាច់ស្រយាល

៩. **សិស្ស**រៀនមិនចេះនៅភូមិសិក្សា១នាំមកនូវបន្ទុកដល់ភូមិសិក្សាបន្ទាប់ ?

១០. **គ្រូបង្រៀន**ខ្វះវិន័យ មិនសិក្សារៀនសូត្រ មិនបានផ្ដោតកិច្ចការជួយសិស្ស ដោយសារមិនបានអនុវត្តប្រព័ន្ធគ្រប់គ្រងការងាររបស់គ្រូបង្រៀន ដូចគ្នានេះដែរសម្រាប់នាយកសាលារៀន ?

**ដោយឡែកសម្រាប់ប្រព័ន្ធអប់រំវិញ ?**

- *បើមិនដឹង តើយើងអាចដឹងថា ប្រព័ន្ធរបស់យើងកំពុងស្ថិតនៅទីណាទៅនៃកម្រិតគុណភាពអប់រំអន្តរជាតិ ?*
- *ហើយតើថ្ងៃនេះយើងដឹងឬទេ ?*
- *យើងដឹងពីហេតុការណ៍ PISA-D, SEAPLM, NAs*
- *តើយើងហ៊ានស្មោះត្រង់ជាមួយឫសគល់របស់វាទេ !*

# PISA 2018


PISA 2018 worldwide ranking
average score of math, science and reading
factsmaps.com
Source: OECD, 2018-2019
The Program for International Student Assessment (PISA) is a worldwide study by OECD in 78 nations of 15-year-old students' scholastic performance on mathematics, science and reading.
above 500
450-500
below 450
GREENLAND
CANADA
UNITED STATES
RUSSIA
CHINA
MONGOLIA
KAZAKHSTAN
BRAZIL
INDONESIA
AUSTRALIA
Above 500
1. China (B-S-J-Z)* 578.7
2. Singapore 556.3
3. Macao 542.3
4. Hong Kong 530.7
5. Estonia 525.3
6. Japan 520.0
6. South Korea 519.7
8. Canada 516.7
Taiwan 516.7
10. Finland 516.3
11. Poland 513.0
12. Ireland 504.7
13. Slovenia 503.7
United Kingdom 503.7
15. New Zealand 502.7
16. Netherlands 502.3
17. Sweden 501.0
18. Denmark 500.3
Germany 500.3
20. Belgium 500.0
* Beijing, Shanghai, Jiangsu, Zhejiang
Between 450-500
21. Australia 499.0
22. Switzerland 498.0
23. Norway 496.7
24. Czechia 495.3
25. United States 495.0
26. France 493.7
27. Portugal 492.0
28. Austria 491.0
29. Latvia 487.3
30. Russia 487.1
31. Iceland 481.3
32. Lithuania 479.7
33. Hungary 479.3
34. Italy 477.0
35. Luxembourg 476.7
36. Belarus 472.3
37. Croatia 471.7
38. Slovakia 469.3
39. Israel 465.0
40. Turkey 462.7
Ukraine 462.7
42. Malta 459.0
43. Greece 453.3
Below 450
44. Serbia 442.3
45. Cyprus 438.0
46. Chile 437.7
47. Un. Arab Emirates 433.7
48. Malaysia 431.0
49. Romania 428.0
50. Bulgaria 426.7
51. Moldova 424.3
52. Uruguay 423.7
53. Brunei 423.0
54. Montenegro 422.0
55. Albania 419.7
56. Jordan 416.0
Mexico 416.0
58. Costa Rica 414.7
59. Qatar 413.3
60. Thailand 412.7
61. Colombia 405.3
62. Kazakhstan 402.3
Azerbaijan 402.3
Bosnia and Herz. 402.3
65. Peru 401.7
66. Brazil 400.3
67. North Macedonia 400.0
68. Argentina 395.0
69. Georgia 387.0
70. Saudi Arabia 386.0
71. Indonesia 382.0
72. Lebanon 376.7
73. Morocco 368.0
74. Panama 365.0
75. Kosovo 361.3
76. Philippines 350.0
77. Dominican Rep. 334.3


Performance in Reading, Mathematics and Science
Science
Reading
Mathematics
600
550
500
450
400
350
300
250
Senegal
Zambia
Cambodia
PISA-D average
Paraguay
Guatemala
Honduras
Lower-middle income average
Ecuador
Indonesia
Upper-middle income average
Thailand
ASEAN average
OECD average
B-S-J-G (China)
Vietnam
Chinese (Taipei)
Source: PISA 2015 and PISA for Development Databases.

## COMPARING STUDENT PROFICIENCY WITH BASIC LEVEL



Cambodia, 8% of students achieve the minimum level of proficiency in reading and 10% of students achieve the minimum level of proficiency in mathematics.




## LEARNING PROFICIENCY OF CAMBODIA IN PISA-D AND PISA MEMBERS IN 2015






https://www.oecd.org/pisa/pisa-for-development/database/

## Score-point difference in reading, mathematics and Science between Public and Private schools




*Source:* PISA for Development Database.

# Southeast Asian Primary Learning Metrics
## (SEA-PLM 2019) Cont.

2

**Reading:** Cambodian students outperform students from Laos PDR and Philippines

**Writing:** Cambodian students outperform students from Laos PDR only

**Mathematics:** Cambodian students outperform students Laos PDR, Myanmar and Philippines




3



# Southeast Asian Primary Learning Metrics
## (SEA-PLM 2019)




- ដោយខ្មែរសម្រាប់ប្រព័ន្ធអប់រំវិញ តើចាំបាច់ត្រូវដឹងឬទេ?

- ហេតុអ្វី?

## ចាំបាច់ត្រូវដឹង! ព្រោះ...

- «កសាងប្រព័ន្ធអប់រំ ផ្តល់សេវាអប់រំសាធារណៈមាន សក្តិសិទ្ធភាពជានាសិស្សម្នាក់ៗ បំពេញបាននូវសមត្ថភាពចាកចេញពីភាពក្រីក្រ និងរកបានចំណូលមធ្យមកម្រិតខ្ពស់តាមទេពកោសល្យរបស់គេម្នាក់ៗ»

# ធ្វើកិច្ចការ១នេះបាន

«កសាងប្រព័ន្ធអប់រំ ផ្តល់សេវាសាធារណៈអប់រំមានស័ក្តិសិទ្ធភាពជានាសិស្សម្នាក់ៗបំពេញបាននូវសមត្ថភាពខ្ពស់បំផុតកម្រិតអន្តរជាតិ តាមទេពកោសល្យរបស់គេម្នាក់ៗ»

យើងត្រូវការ ការដឹកនាំ និងការគ្រប់គ្រងសម្រាប់អនុវត្តចក្ខុវិស័យនិងសុខដុមនីយកម្មការកែទម្រង់៣ប្លុក១

# វាយតម្លៃខ្លួនអ្នកអំពីស្ថានភាពនៃវិជ្ជាជីវៈ និងធាតុផ្សំនៃសុខុមាលភាព




- គ្រប់សកម្មភាពគឺបានបំពេញនិយមន័យ ការរៀនសូត្រ ដែលត្រូវកើតឡើងពេញមួយជីវិត « ជាដំណើរនៃការទទួលយកនូវ ការយល់ដឹងពីកិច្ចការថ្មីមួយឬរឿងថ្មីមួយ អនុវត្តការយល់ដឹងនោះ នាំឱ្យមានអត្តចរិតថ្មី ចរិយាថ្មី កសាងបាននូវពិសោធន៍ ឈានទៅបង្កើតបាននូវចំណេះដឹងថ្មីពីកិច្ចការថ្មីមួយ ហើយបុគ្គលនោះនឹងបណ្ដុះបាននូវចរិយាស្វែងចង់ដឹងនិងចង់យល់គ្រប់ពេលវេលា»
- កិច្ចការដដែលដូចជា ការធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្ស ត្រូវតែផ្លាស់ប្តូរបរិបទនៃការអនុវត្តពីប្រទេសមានចំណូល មធ្យមកម្រិតទាប ទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងត្រៀមរួចស្រេចទៅប្រទេសមានចំណូលខ្ពស់

# អភិក្រមប្រចំនួន៤ «អត្ថន័យសម្រាប់វិស័យអប់រំ?»

1

**១. អភិក្រមរក្សាគំហើញទាំងមូល** កម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន

2

**២. អភិក្រមចូលរួមចំណែកតាមតួនាទី** កម្មវិធីកែទម្រង់នីមួយៗបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និង បទប្បញ្ញត្តិជាធរមាន

## អភិក្រមប្រចំនួន៤ «អត្ថន័យសម្រាប់វិស័យអប់រំ?»

**៣. អភិក្រមរក្សាភាពជាម្ចាស់និងកិច្ចសហការ** *គឺការគោរពភាពជាម្ចាស់លើវឌ្ឍភាពនិងគណនេយ្យភាពចំពោះកម្មវិធីកំណែទម្រង់របស់ខ្លួនផងនិងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកំណែទម្រង់ផ្សេងទៀតផង*

**៤. អភិក្រមបុរេសកម្ម** *គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នាតាមរយៈយន្តការសម្របសម្រួលការកែទម្រង់៣ឬក១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយៗ*

**២០១៧ ដល់ ២០២២**
**អ្នកមាននិជ្ជាជីវៈដំបូង**
**មានកម្រិតបរិញ្ញាប័ត្រ**
**ធ្វើឱ្យសាលារៀនមួយ**
**មានដំណើរការ**
**«អនុវត្តគំនិត១ SBM»**

**២០២២ ដល់ ២០២៦**
**អ្នកឯកទេសអប់រំ**
**មានកម្រិតអនុបណ្ឌិត**
**ធ្វើឱ្យសាលារៀនទាំងអស់**
**ក្នុងឃុំ/សង្កាត់មានដំណើរការ**
**«អនុវត្តគំនិត១SBM**
**បូក ការដឹកនាំ, SCS»**

**២០២៦ដល់២០៣០**
អ្នកឯកទេសអប់រំជាន់ខ្ពស់
មានកម្រិតបណ្ឌិត
ធ្វើឱ្យសាលារៀនទាំងអស់
ក្នុងស្រុកមានដំណើរការ
ជាសាលាអន្តរជាតិ
«អនុវត្តគំនិត១SBM
បូក ការដឹកនាំ, SCS
បូក គោលនយោបាយ, SD»

9/3/20XX Presentation Title 21

***បេសកកម្ម៖*** *(ប្រាប់ពីកិច្ចការ)*

*១ ផលិតសិស្សមានបំណិនខ្ពស់សម្រាប់ **ជីវិតនិងការងារ** និងត្រៀមត្រៀមគ្រូចស្រេចចូលរៀននៅមហាវិទ្យាល័យ ឬ ចូលរួមក្នុងទីផ្សារការងារ*

*២ កែលម្អការអនុវត្តរបស់សាលារៀន បំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធិភាព (សាលារៀនគំរូ)។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើង លើភាពក្រីក្រ យេនឌ័រ ពិការភាព ឬ ជនជាតិភាគតិច។*

***គោលបំណង៖*** *(ប្រាប់ពីផលសម្រេច ជាទិន្នន័យអាចវាស់បាន)*

*១ សិស្ស៨០ ទៅ ៨៥% មានបំណិនខ្ពស់សម្រាប់ **ជីវិតនិងការងារ** និងត្រៀមត្រៀមគ្រូចស្រេចចូលរៀន នៅមហាវិទ្យាល័យ ឬ ចូលរួមក្នុងទីផ្សារការងារ នៅ៦ឆ្នាំក្រោយ*

*២ សាលារៀនបំពេញបាននូវ ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន នៅ៦ឆ្នាំក្រោយ។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើង លើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច។*

22

## សម្ព័ន្ធភាពនាំមុខសម្រាប់ការងារកំណែទម្រង់
## ខ្លឹមសារសំខាន់គឺ ផ្តោតលើសមត្ថភាព




## សេវាសាធារណៈបម្រើផលប្រយោជន៍ប្រសើរបំផុតសម្រាប់ប្រជាពលរដ្ឋ ជៀសផុតភាពក្រីក្រសិក្សារៀនសូត្រ ភាពក្រីក្រសង្គម និងភាពក្រីក្រហិរញ្ញវត្ថុ តាមក្រុមគោលដៅសេវាដែលកំណត់រយៈពេល៦ឆ្នាំ ៣ឆ្នាំ និងប្រចាំឆ្នាំ



# តើមាន ឧបសគ្គអ្វីខ្លះ នាបច្ចុប្បន្ន ដែលការដឹកនាំនិងគ្រប់គ្រង ត្រូវប្រឈមដោះស្រាយ?

- **មិនហ៊ានធ្វើអ្វីថ្មី** សមត្ថភាពដឹកនាំខ្សោយ បុគ្គលិកមិនពេញចិត្ត ខ្វះផែនការមិនច្បាស់លាស់ ខ្វះអភិបាលកិច្ច  មិនមានគំរូជាម៉ូដែល
- **បង្រៀនទ្រឹស្តី បង្រៀនសិស្សមិនចេះ** មិនមានកម្មវិធីបំណិន ខ្វះបច្ចេកទេស សិស្សខ្វះសមត្ថភាពគ្រឹះរៀនសូត្រ
- **ខ្វះការចូលរួមនិងស្ម័គ្រចិត្ត** ខ្វះការប្រកួតប្រជែង ខ្វះការគ្រប់គ្រងពេលវេលា មិនមានទិន្នន័យ មិនទុកជាការងារស្នូល ខ្វះការលើកទឹកចិត្ត ខ្វះសមត្ថភាពគ្រប់គ្រងនិងបច្ចេកវិទ្យា ប្រព័ន្ធមិនដើរ មនសិការការងារទាប មិនទទួលយកការរិះគន់ ខ្វះកិច្ចសហការណ៍សាលារៀនជាមួយសហគមន៍និងឯកជន មន្ត្រីនៅខ្ជិលនិងខ្លាច
- **ខ្វះលុយ ខ្វះគ្រូ ខ្វះជាតុចូលផ្សេងទៀត** ជាតុចូលមិនត្រូវតាមតម្រូវការផលិត...

**តើធាតុណានាំមានឥទ្ធិពលលើសគេក្នុងធាតុផ្សេងទៀត?**

- បំណិន STEM ទាប
- ចូលរៀនទាប
- ក្រីក្រលុយ
- រៀនផលិតអ្វីមិនបាន
- រៀនមិនចេះ
- ចំណូលសាលាទាប
- ខ្វះបំណិនចិត្តសង្គម
- មិនមានសង្ឃឹម
- លុយសាលាពីរដ្ឋទាប
- មិនទុកចិត្ត
- មិនចេះអង់គ្លេស
- ចំណូលទាប

**តើធាតុណានាំមានឥទ្ធិពលលើសគេក្នុងធាតុផ្សេងទៀត?**

- បំណិន STEM ទាប
- ចូលរៀនទាប
- ក្រីក្រលុយ
- រៀនផលិតអ្វីមិនបាន
- រៀនមិនជោគជ័យ
- ចំណូលសាលាទាប
- ខ្វះបំណិនចិត្តសង្គម
- មិនមានសង្ឃឹម
- លុយសាលាពីរដ្ឋទាប
- មិនទុកចិត្ត
- មិនចេះអង់គ្លេស
- ចំណូលទាប

## តើធាតុណានាំមានឥទ្ធិពលលើសគេក្នុងធាតុផ្សេងទៀត?




## កិច្ចការដឹកនាំធំៗ ឆ្ពោះចក្ខុវិស័យ២០៣០ និង២០៥០

១. បង្កើតឱ្យមាននូវការយល់ឃើញថាអង្គភាពមានភាពអាសន្ន

២. បង្កើតសម្ព័ន្ធភាពនាំមុខសម្រាប់ការងារកំណែទម្រង់

៣. ផលិតទស្សនៈវិស័យ (ចក្ខុវិស័យ២០៣០និង២០៥០) ច្បាស់លាស់

៤. រំលែកទស្សនៈវិស័យដល់គ្រប់អ្នកពាក់ព័ន្ធ

៥. ផ្តល់អំណាច និងកសាងសមត្ថភាពមនុស្សជម្នះឧបសគ្គ ដើម្បីសម្រេចទស្សនៈវិស័យ

៦. ធានាឱ្យបាននូវការផលិតភាពជោគជ័យក្នុងរយៈពេលខ្លី

៧. សរុបភាពជោគជ័យទាំងអស់ កសាងគោលនយោបាយ និងបន្តដំណើរទៅមុខជាផ្លូវការ

៨. ផ្តោតរឹងមាំលើការផ្លាស់ប្តូរ នាំការផ្លាស់ប្តូរទៅមុខ និងអនុវត្តផែនការទប់ទល់ការប្រឆាំង

## កុមារអាយុ ៥ឆ្នាំ៖ ៦៣,១%, អត្រាបញ្ចប់នៅបឋម៖ ៨៨,៧%, នៅមធ្យមសិក្សា៖ ៥៣,១%



**កិច្ចព្រមព្រៀងសមិទ្ធកម្ម**

**រវាង**

**ក្រសួងអប់រំ យុវជន និងកីឡា**

**និង**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ស្តីពី**

**ការអនុវត្តថវិកាសមិទ្ធកម្ម**

**ឆ្នាំ២០២៣**

**កិច្ចព្រមព្រៀងសមិទ្ធកម្ម**
**រវាង**
**ក្រសួងអប់រំ យុវជន និងកីឡា**
**និង**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង **ក្រសួងអប់រំ យុវជន និងកីឡា** និង **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨, ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២២, សារាចរណែនាំក្នុងគោលដៅអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងក្នុងគោលបំណងលើកកម្ពស់ការចូលរួមអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា "ថវិកាសមិទ្ធកម្ម" ក្នុងស្មារតីតម្រូវឱ្យមានការវាស់វែងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីតាមរយៈសូចនាករសមិទ្ធកម្ម ដោយផ្សារភ្ជាប់រវាងលទ្ធផលក្នុងឆ្នាំ និងអាទិភាពគោលនយោបាយសម្រាប់ធ្វើការសម្រេចចិត្តលើការវិភាជថវិកា ឬ ធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀងក្នុងការអនុវត្ត ដូចមានចែងក្នុងប្រការខាងក្រោម៖**

**ប្រការ១៖ វិសាលភាពការងារ និងតម្លៃកិច្ចព្រមព្រៀង**

ក្រសួងអប់រំ យុវជន និងកីឡា យល់ព្រមទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្រោមការពិនិត្យ និងសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការអនុវត្តកម្មវិធីចំនួន ០៥ ដែលមានតម្លៃទឹកប្រាក់សរុបចំនួន ៣៧៧ ៤៧៨,៦លានរៀល (បីរយចិតសិបប្រាំពីរប៊ីលាន បួនរយចិតសិបប្រាំបីលាន ប្រាំមួយរយពាន់រៀល) ជាតម្លៃកិច្ចព្រមព្រៀង។ កម្មវិធីទាំង ០៥ មានដូចខាងក្រោម៖

១. កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ
តម្រូវការទឹកប្រាក់សរុបចំនួន ៦២ ៨៩០,៨លានរៀល
(ហុកសិបពីរប៊ីលាន ប្រាំបីរយកៅសិបលាន ប្រាំបីរយពាន់រៀល)

២. កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ
តម្រូវការទឹកប្រាក់សរុបចំនួន ៣៣ ៣៥៨,៩លានរៀល
(សាមសិបបីប៊ីលាន បីរយសែសិបប្រាំបីលាន ប្រាំបួនរយពាន់រៀល)

៣. កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
តម្រូវការទឹកប្រាក់សរុបចំនួន ៤៣ ៨៧៣,៧លានរៀល
(សែសិបបីប៊ីលាន ប្រាំបីរយចិតសិបបីលាន ប្រាំពីររយពាន់រៀល)

ទំព័រ ២នៃ ១៣

៤. កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន
តម្រូវការទឹកប្រាក់សរុបចំនួន ៩ ០០៧,៧លានរៀល
(ប្រាំបួនប៊ីលាន ប្រាំពីរលាន ប្រាំពីររយពាន់រៀល)

